# ព្យាណូ សម្រាប់ ប្រូហ្វីត



*ក្មេងប្រុសម្នាក់ឈ្មោះប្រូហ្វីត មានគោលដៅសំខាន់ពីរ ។*

**ដោយ រីឆាឌ អិម រ៉មនី**
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

« *តន្ត្រី គឺជាភាសាមួយដែលមនុស្សគ្រប់រូបអាចយល់បាន* » (សៀវភៅចម្រៀងកុមារ *ទំព័រ* iii ) ។

ប្រូហ្វីតចូលចិត្តតន្ត្រីណាស់ ។ ជាពិសេសគាត់ចូលចិត្តចម្រៀងកុមារ និងទំនុកតម្កើងរបស់សាសនាចក្រ ។ គាត់ច្រៀងរហ៊ឹមៗតាមចង្វាក់ភ្លេងពេញមួយថ្ងៃៗ ។ គាត់ស្រមៃថាខ្លួនគាត់អង្គុយនៅព្យាណូមួយ កំពុងលេងចម្រៀងដែលគាត់ចូលចិត្ត ។ គាត់ក៏ស្រមៃថា ខ្លួនគាត់កំពុងបង្រៀនមនុស្សដទៃទៀតឲ្យលេងផងដែរ ។

មានបញ្ហាតែមួយគត់ ។ គាត់មិនមានព្យាណូទេ ។

ថ្ងៃមួយ ប្រូហ្វីតបានមានការសម្ភាសជាមួយនឹងប៊ីស្សពរបស់គាត់ ។

ប៊ីស្សពបានសួរថា « តើក្មួយមានដាក់គោលដៅសម្រាប់កម្មវិធីកុមារ និងយុវវ័យដែរឬទេ ? »

ប្រូហ្វីតបានតបថា « បាទ » ។ « ខ្ញុំចង់រៀនលេងព្យាណូ » ។

ប៊ីស្សពបាននិយាយថា « នោះគឺជាគោលដៅដ៏ល្អមួយ » ។

ប្រូហ្វីតបាននិយាយថា « ហើយនៅពេលខ្ញុំសម្រេចគោលដៅនោះហើយ ខ្ញុំមានគោលដៅមួយទៀត ។ ខ្ញុំចង់បង្រៀនមនុស្ស ២០នាក់ទៀតពីរបៀបលេងផងដែរ » ។

ប៊ីស្សពបាននិយាយថា « ក្មួយមានគោលដៅដ៏ល្អពីរ » ។

ប្រូហ្វីតបាននិយាយថា « ហើយខ្ញុំមានបញ្ហាមួយ » ។ « ខ្ញុំអត់មានព្យាណូទេ » ។

« មែនហើយ ចាំមើលថាយើងអាចធ្វើអ្វីបានខ្លះ » ។

នៅសាសនាចក្រនៅថ្ងៃអាទិត្យបន្ទាប់នោះ ប៊ីស្សពបានប្រាប់ប្រូហ្វីតថា គាត់បានរកអ្នកផ្សព្វផ្សាយសាសនាជាប្ដីប្រពន្ធមួយគូដែលអាចបង្រៀនគាត់បាន ។ ពួកគាត់នឹងយកព្យាណូមកឲ្យប្រូហ្វីត និងអ្នកផ្សេងទៀតដើម្បីហាត់លេង ។ ពួកគាត់ចង់បង្រៀនមនុស្សជាច្រើនពីរបៀបលេងព្យាណូ ។







សូមមើលវីដេអូអំពីរឿងនេះនៅ childrenandyouth.churchofjesuschrist.org ។ សូមចុចត្រង់ « ដំណើររឿងទាំងឡាយ» ។





**សូមមើល *ចូរមកតាមខ្ញុំ* សម្រាប់ គោលលទ្ធិ និង សេចក្ដីសញ្ញា ២៣–២៦ ។**

ប៊ីស្សពបាននិយាយទៅកាន់មនុស្សគ្រប់គ្នា ។ ប្រូហ្វីតបាននិយាយទៅកាន់មនុស្សគ្រប់គ្នា ។ គ្រួសាររបស់ប្រូហ្វីតបាននិយាយទៅកាន់មនុស្សគ្រប់គ្នា ។ មិនយូរ វួដទាំងមូលបាននិយាយអំពីមេរៀនព្យាណូ ។ មនុស្សផ្សេងទៀតក៏និយាយពីព្យាណូផងដែរ ។

ប្រូហ្វីតបានប្រាប់ប៊ីស្សពថា « មិត្តខ្ញុំជាច្រើនដែលមិនមែនជាសមាជិកក៏ចង់រៀនផងដែរ » ។

ប៊ីស្សពបាននិយាយថា « យើងពិតជាស្វាគមន៍ពួកគេ » ។ « ពួកអ្នកផ្សព្វផ្សាយសាសនានឹងឲ្យសៀវភៅមួយក្បាលដល់ក្មួយ ហើយជួយក្មួយរៀនមេរៀនទាំងនោះ ។ ហើយបន្ទាប់ពីក្មួយរៀន ក្មួយអាចជួយពួកគាត់បង្រៀនអ្នកគ្រប់គ្នាផ្សេងទៀត » ។

« នេះគឺជាគោលដៅទីពីររបស់ខ្ញុំ ! » ប្រូហ្វីតបាននិយាយ ។

មិនយូរប៉ុន្មាន ប្រូហ្វីតបានហាត់ព្យាណូជាមួយនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ គាត់ចូលចិត្តរៀនពីអត្ថន័យនៃសទ្ទសញ្ញាភ្លេងនីមួយៗ និងឮសទ្ទសញ្ញាភ្លេងទាំងនោះរួមគ្នាបង្កើតជាចម្រៀងមួយ ។ មិត្តពីរនាក់របស់គាត់មកពីព្រះវិហារ ឈ្មោះ ខេវិន និង អាឡិចហ្សានឌ័រ ក៏កំពុងតែរៀនផងដែរ ។ មួយខែក្រោយមក ក្មេងប្រុសទាំងបីនាក់ចាប់ផ្ដើមបង្រៀនផងដែរ ។

រៀងរាល់ថ្ងៃ ក្មេងប្រុសទាំងនោះបង្រៀនថ្នាក់ព្យាណូនៅអគារសាសនាចក្រ ។ ពីដំបូងមានសិស្សប្រហែល ១០នាក់ បន្ទាប់មក ២០នាក់ បន្ទាប់មកទៀត ៥០នាក់ !

« វាសប្បាយណាស់ ! » ខេវិនបាននិយាយនៅថ្ងៃមួយ ពេលចប់ថ្នាក់ ។

អាឡិចហ្សានឌ័របាននិយាយថា « ខ្ញុំគិតថា ព្រះវរបិតាសួគ៌មានព្រះទ័យរីករាយដោយសារយើងកំពុងជួយមនុស្សដទៃទៀតឲ្យរៀន » ។

ប្រូហ្វីតបានងក់ក្បាល ។ គោលដៅរបស់គាត់បានកំពុងជួយដល់មនុស្សជាច្រើនរួចទៅហើយ ។

ប៉ុន្តែមានអ្វីមួយផ្សេងទៀតដែលបានធ្វើឲ្យប្រូហ្វីតសប្បាយចិត្ត ។ កាលដែលសិស្សផ្សេងៗទៀតហាត់ចម្រៀងថ្នាក់កុមារ ពួកគេក៏កំពុងរៀនអំពីព្រះវរបិតាសួគ៌ផងដែរ ។ ពួកគេខ្លះបានសួរប្រូហ្វីតថាបើពួកគេអាចរៀនបន្ថែមទៀតអំពីសាសនាចក្របាន ។

ហើយតាមពិតទៅ មនុស្សមួយចំនួនដែលពីដំបូងឡើយ បានរៀនអំពីសាសនាចក្រដោយសារតែមេរៀនព្យាណូ បានទទួលបុណ្យជ្រមុជទឹកនៅទីបំផុត ។

ប្រូហ្វីតបាននិយាយថា « ឥឡូវនេះ យើងទាំងអស់គ្នាចូលរួមជាមួយគ្នា ហើយច្រៀងចម្រៀងដែលយើងចូលចិត្តនៅក្នុងការប្រជុំនានា » ។ ●

*រឿងនេះកើតឡើងនៅ ហ្វ្រេតធើរ អាក្រា ប្រទេសហ្គាណា ។*